**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងរដ្ឋប្បវេណី ៣៣*៤៤

លេខៈ ៣២០

ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០២ **នាមនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខៈ ៣២៦ បានបើកសវនាការជំនុំជំរះរួមក្រុមជាសាធារណៈនៅថ្ងៃទី២៣ខែធ្នូឆ្នាំ២០០៥

ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃឹម** | **ប៉ុណ្ណ** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | វឿល | មួន | ជាចៅក្រម |
| ៣-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៤-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៥-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៦-លោក | យស់ | សូខឿន | ជាចៅក្រម |
| ៧-លោក | គង់ | ភិរុន | ជាចៅក្រម |
| ៨-លោក | ប៉ែន | សារឿន | ជាចៅក្រម |
| ៩-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រមរបាយការណ៍ |
| លោក | **សុខ** | **ម៉ៅ** | ក្រឡាបញ្ជី |

តំណាងមហាអយ្យការ

| | | | |
|---|---|---|---|
| លោក | **ឈួន** | **មាន់ថា** | ជាព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ១១២"ឈ"ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះនូវ **សុខខាង** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរលក់ផ្លែឈើ ទីលំនៅភូមិកំពង់បាយខាងជើង ឃុំកំពង់បាយ ស្រុកកំពង់បាយ ខេត្តកំពត។

ផ្ទេរសិទ្ធិឱ្យឈ្មោះ កង សុផល .

មានមេធាវីលោក ឈុន វិនីតា .

ចុងចម្លើយឈ្មោះ **តាន់ ហ្វុង** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៧៧ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករលក់ឈើមូល ទីលំនៅភូមិកំពង់បាយខាងជើង ឃុំកំពង់បាយ ស្រុកកំពង់បាយ ខេត្តកំពត ។ ឪពុកឈ្មោះតាន់ កាយ(ស) ម្តាយឈ្មោះនាង លៀង"ស"ប្តីឈ្មោះគង់ ប៊ុនឈាន។

មានមេធាវីលោក ស៊ឹម ស៊ីថាន ។

**<u>ចម្បវត្ថុបណ្តឹង</u>** : សុំទាមទារឱ្យរុះរើរោងលក់ឈើ និងជំងឺចិត្ត .

**<u>បណ្តឹងតប</u>** :សុំសិទ្ធិគ្រប់គ្រងដី .

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ២៦៨ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះខូវ សុខផាវ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១១២"ឈ" ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣២០ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់លោក ជុំ ហួង បញ្ជាក់ថា : អ្នកស្រីតាន់ ហួង បានធ្វើរោងអាជីវកម្មលក់ឈើមូលមុខផ្ទះរបស់ខ្លួនពេលខ្លួនចង់រៀបចំផ្ទះពីខាងមុខឱ្យមានភាពល្អ អ្នកស្រីតាន់ ហួង មិនឱ្យធ្វើទើបមានទំនាស់នេះកើតឡើង ។

តាមបណ្តឹងសារត្រឡប់ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៦ ឈ្មោះតាន់ ហួង ថា ផ្ទះដែលឈ្មោះជុំ ហួង គ្រប់គ្រង ជាផ្ទះរបស់យាយខ្លួន ហើយផ្ទះនេះ ខ្លួនបាននៅជាមួយយាយតាំងពីឆ្នាំ១៩៨៣មកម្ល៉េះ ។ ចំណែកឈ្មោះជុំ ហួង ត្រូវជាមា ។ តាំងពីឆ្នាំ១៩៨៣មក គាត់មិនដែលនៅផ្ទះនេះទេទើបឆ្នាំ១៩៩១ គាត់ចូលមកស្នាក់នៅ តែពេលនោះរដ្ឋអំណាចបានចែកដីឱ្យគាត់មួយកន្លែងទៀតដើម្បីរស់នៅដោយឡែក ។ ដើមចោទបានប្រើល្បិចកលគ្រប់យ៉ាង ហើយបានលួចធ្វើប័ណ្ណកម្មសិទ្ធិដោយមិនឱ្យក្មួយណាម្នាក់ដឹងឡើយ ។ ហេតុនេះហើយ ខ្លួនសុំប្តឹងទាមទារ :

- បដិសេធប័ណ្ណកម្មសិទ្ធិ
- ពុំព្រមរើរោងឈើចេញ ហើយប្តឹងសុំទាមទារដី និងផ្ទះមកធ្វើកម្មសិទ្ធិវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៣២ចុះថ្ងៃទី២០ខែមិថុនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់ឈ្មោះជុំ ហួង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលបណ្តឹងសារត្រឡប់ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៦ ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយខាសនឹងគតិច្បាប់ ។

៣-បង្គាប់ឱ្យនារីតាន់ ហួង រុះរើរោងលក់ឈើមូលចេញពីមុខផ្ទះជុំ ហួង ចាប់ពីពេលនេះតទៅ ។

៤-បង្គាប់ឱ្យនារី តាន់ ហួង សងជម្ងឺចិត្ត និងសោហ៊ុយសោដាផ្សេង១ចំនួនមួយលានរៀល សុំលើសពីនេះបដិសេធចោល ។

៥-ឱ្យនារីតាន់ ហួង បង់ប្រាក់ប្រដាប់ក្តីតាមច្បាប់ និងពន្ធសមាមាត្រមួយភាគរយលើតម្លៃផ្ទះដី តាមការជាក់ស្តែង ចាប់ពីពេលសាលក្រមចូលស្ថាពរ ។

សាលក្រមនេះជំនុំជំរះជាសាធារណៈ ប្រកាសជាសាធារណៈចំពោះមុខគូក្តី សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេលពីរខែ គិតចាប់ពីពេលនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៧ របស់អ្នកស្រីតាន់ ហួង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៣២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩៧ របស់តុលាការកំពត ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបលេខ ៤៥ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់បញ្ចូលឈ្មោះតាន់ ស៊ីម ភេទស្រី ,តាន់ ហ្កេច ភេទស្រី,តាន់ ឆាយ ភេទប្រុស ,តាន់ មួយ ភេទស្រី និងឈ្មោះតាន់ យូរ ភេទស្រី ដែលជាបងប្អូននាងតាន់ ហួង មកដាក់ខាងភាគីតាន់ ហួង (ចុងចម្លើយ) ។

២-សាលដីកានេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៤៨ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៤-៨-៩៧ របស់ឈ្មោះតាន់ ហួង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៣២ចុះថ្ងៃទី២០-៦-៩៧ របស់តុលាការខេត្តកំពត ចោលជាអសារបង់ ។

៣-ប្រគល់ផ្ទះ និងដីទំនាស់ស្ថិតនៅភូមិកំពង់បាយ ឃុំកំពង់បាយ ស្រុកកំពង់បាយ ខេត្តកំពត ឱ្យទៅឈ្មោះ តាន់ ហួង, តាន់ ស៊ីម, តាន់ ហ្កេច, តាន់ ឆាយ, តាន់ មួយ និង តាន់ យូរ កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី១៣.០០០៛ ដែលឈ្មោះតាន់ ហួង បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់

ដីកាកោះ៥.០០០៛ និងអាជ្ញាធរតុលាការ៥.០០០៛ ។កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះ ជុំ ហួង សងប្រាក់នេះទៅឈ្មោះតាន់ ហួង វិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រ១% លើតម្លៃផ្ទះ និងដីទំនាស់ ។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភ្ញី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៦២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨ របស់លោកជុំ ហួង បានប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៤៨ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៨ របស់ឈ្មោះជុំ ហួង ។

បានឃើញសារណាតបចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះតាន់ ហួង ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២២២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០០ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣៦២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨ របស់លោកជុំ ហួង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៦៤៨ ចុះថ្ងៃទី១២-១០-៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៩៤ ចុះថ្ងៃទី ៣០-១១-៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោកជុំ ហួង បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតំរូវឱ្យអ្នកស្រីតាន់ ហួង សងប្រាក់១៩.០០០៛នេះ ទៅដើមចោទវិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០០ ។

បានឃើញសាលដីការបៀបលេខ ១៣"ឈ" ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-បង្គាប់ឱ្យអាជ្ញាធរជំនាញចុះគូសប្លង់ទីតាំងដីទំនាស់ ដោយមានការចូលរួមរបស់ភាគីទំនាស់ និងចង្អុលបង្ហាញពីទំហំដី ដែលខ្លួនអះអាងថា បានកាន់កាប់កន្លងមក និងឱ្យអាជ្ញាធរជំនាញធ្វើរបាយការណ៍ពីប្រវត្តិនៃការកាន់កាប់ដីទំនាស់របស់គូភាគី ។

២-បង្គាប់ឱ្យភាគីនៃរឿងក្ដី ជូនភស្តុតាងមកសាលាឧទ្ធរណ៍ បើសិនជាមាន ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចំលើយកំបាំងមុខដើមចោទ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤២"ឈ" ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ ២៥ ចុះថ្ងៃទី៩-៥-២០០១ របស់សាលាឧទ្ធរណ៍តាមអំណាចសាលដីកាលេខ ២២២ ចុះថ្ងៃទី២៤-១០-០០ របស់តុលាការកំពូល ។

២-ទទួលពាក្យបណ្ដឹងរបស់ឈ្មោះជុំ ហួង ចុះថ្ងៃទី១៨-១១-៩៦ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-ប្រគល់ផ្ទះ និងដីទំនាស់ស្ថិតនៅភូមិកំពង់បាយខាងជើង ឃុំកំពង់បាយ ស្រុកកំពង់បាយ ខេត្តកំពត ឱ្យទៅឈ្មោះតាន់ ហួង ,តាន់ ស៊ីម, តាន់ ហ្គេច, ជុំ ឆាយ, ជុំ ឡេង ,តាន់ មួយ, តាន់ ឃួរ កាន់កាប់ជាកម្មសិទ្ធិតទៅ តាមគំនូសប្លង់បង្ហាញទីតាំងដីទំនាស់ ។

៤-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល គឺ ពន្ធចុះបញ្ជីក្ដីនិងពន្ធហ្មឹងចំនួន២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការចំនួន ៥.០០០៛ សរុប១៣.០០០៛ ។ កាលបើផុតបណ្ដឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះខូវ សុខផាវ បង់ពន្ធសមាមាត្រ១% លើតំលៃដីទំនាស់ ។ ប្រាក់ពន្ធសមាមាត្រនេះ ដាក់ចូលថវិការដ្ឋ៨០% និងត្រូវបានរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៥-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខ តាន់ ហួង កំបាំងមុខ ខូវ សុខផាវ ។ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ ២៤៤ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២ របស់ឈ្មោះខូវ សុខផាវ ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤២"ឈ" ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១១២"ឈ" ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងទាស់របស់ឈ្មោះខូវ សុខផាវ ចុះថ្ងៃទី២៤-៤-២០០២ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-ទទួលស្គាល់ការផ្ទេរសិទ្ធិពីឈ្មោះខូវ សុខផាវ ទៅឱ្យឈ្មោះចាន់ សារី ធ្វើជាតំណាងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣-តំកល់សាលដីកាកំប៉ាំងមុខលេខ ៤២"ឈ" ចុះថ្ងៃទី១២-៣-២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការ និងសំរេចបន្ថែមក្នុងចំណុចទី៣ នៃសាលដីកានេះ នូវឈ្មោះពីរនាក់ទៀត ដែលត្រូវបានចំណែកដីទាស់ គឺឈ្មោះជុំ ជី និង ជុំ ហ៊ង ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ២៦៨ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះខូវ សុខផាវ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១១២"ឈ" ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបលេខ ១៦៧ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបធ្វើការស៊ើបអង្កេតបន្ថែម ។ ក្នុងករណីចាំបាច់ ចាត់ក្រុមប្រឹក្សាជំនុំជំរះចុះពិនិត្យដល់ទីតាំងទំនាស់ ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤។

បានឃើញគំនូសប្លង់បង្ហាញទីតាំងដីទំនាស់ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះតុលាការកំពូល បានអង្កេតត្រឹមត្រូវហើយ សូមក្រុមប្រឹក្សាជំនុំជំរះចុះ ។

បានស្តាប់ចំលើយរបស់ឈ្មោះកង សុផង បានទទួលសិទ្ធិពីឈ្មោះខូវ សុខផាវ បានលើកឡើងថា : ជុំ ហួង ជាកូនយាយ ផៃ គី បង្កើត ហើយខូវ សុខផាវ ជាប្រពន្ធស្របច្បាប់របស់ជុំ ហួង អ្នកទាំងពីរ(ជុំ ហួង និង ខូវ សុខផាវ) រៀបការឆ្នាំ១៩៨០ ការហើយបានកូនពីរនាក់ឈ្មោះជុំ វាសនា និងជុំ សំណាង ។ ពេល ជុំ ហួង រៀបការហើយ មកនៅលើផ្ទះទំនាស់ពុំមាននរណាក្រៅពីយាយផៃ គី ទេ ។ សព្វថ្ងៃចុងចំលើយនៅពីលើដីទំនាស់ខាងមុខ ឯដើមចោទក៏មានផ្ទះលើដីទំនាស់ដែរ ក្រៅពីដីនិងផ្ទះទំនាស់នេះ ខូវ សុខផាវ ពុំមានផ្ទះ និងដីឯណាទៀតទេ ។ ក្រោយពីរដ្ឋអំណាចចែកដីឱ្យមក ជុំ ហួង បានសុំធ្វើប័ណ្ណ តែមេត្រួសារគឺ យាយ ផៃ គី ទេចំពោះការដែល ជុំ ហួង សុំដូរមេត្រួសារ សុំដកប័ណ្ណចាស់ធ្វើប័ណ្ណថ្មី ខ្លួនមិនដឹងទេ ។ កូនពីរនាក់ ជុំ វាសនា កើតឆ្នាំ១៩៨០ ឯ ជុំ សំណាង កើតឆ្នាំ១៩៨៤ ជាកូនរបស់ដើមចោទ និងប្តី ។

បានស្តាប់ចំលើយរបស់ឈ្មោះតាន់ ហួង នាពេលសវនាការថា : ដីទំនាស់ ពួកខ្លួនបានចូលរស់នៅជាមួយយាយផៃ គឺ តាំងពីឆ្នាំ១៩៧៩មកម្ល៉េះ ឆ្នាំ១៩៧៩ ជុំ ហួង នៅប្រទេសវៀតណាមទេ ដល់ឆ្នាំ១៩៨៣ មកពីវៀតណាម ការប្រពន្ធទីពានៅភូមិអណ្តូងខ្មែរ មុនចូលនៅជាមួយខ្លួនលើផ្ទះទំនាស់១៩៨៦ ជុំ ហួង នៅកោះកុង ការប្រពន្ធឈ្មោះ ខូវ សុខផាវ នេះ ហើយជាប្រពន្ធទី៤ ទើបចូលមកនៅជាមួយខ្លួន កន្លងមកជុំ ហួង បានលួងលោម និងបោកប្រាស់ខ្លួនថាឱ្យប័ណ្ណគ្រួសារអញមក យកដូរថ្មីឱ្យ ព្រោះអញអ្នកធ្វើការស្រាប់ ដឹងអ្វីគាត់ដូរដាក់ឈ្មោះគាត់ពេលយាយ ផៃ គឺ ស្លាប់ បែរដេញខ្លួនចេញពីផ្ទះ បងប្អូនខ្លួន៧-៨នាក់ គ្មានផ្ទះ និងដីនៅទេដើរសុំគេជ្រក ខ្លួនប្តឹងឱ្យអាជ្ញាធរភូមិ-ឃុំនិងប្តឹងទៅតុលាការតែម្តង ចំពោះអ្នកចូលមកឆ្លើយជំនួសខូវ សុខផាវ ពេលនេះ មិនដឹងអ្វីទាំងអស់ មិនដឹងលេចមុខពីណាទេ ដី និងផ្ទះទំនាស់ជារបស់ខ្លួនកន្លងមក ខូវ សុខផាវ ដើរនិយាយប្រាប់គេថា : ដីនិងផ្ទះនេះ មិនមែនរបស់អញទេ ធ្វើឱ្យប្រែង (តាន់ ហួង)រលាយ គឺធ្វើឱ្យខ្លួនវេទនាមែន។បងប្អូនបង្កើតខ្លួន ដូចមានឈ្មោះក្នុងសំណុំរឿងហើយចំណែកជុំ វាសនា និងជុំ សំណាង មិនមែនកូនបង្កើត ជុំ ហួង ទេ ខូវ សុខផាវ រួមគ្នាជាមួយជុំ ហួង គ្មានកូនបង្កើតទេ កូនទាំងពីរនាក់នេះ កូនប្តីមុនរបស់ខូវ សុខផាវ ទេ ។ បង្ហាន់ដៃដី និងប័ណ្ណគ្រួសារខ្លួន ជុំ ហួង យកដុតចោលហើយ (ច្បាប់ដើម) ដូចសុរិយោដីបញ្ជាក់ស្រាប់ ជុំ ហួង ចូលនៅឆ្នាំ១៩៨៦ មានសិទ្ធិអ្វីមកចែកមរតក សព្វថ្ងៃបងប្អូនខ្លួននៅលើផ្ទះ និងដីនេះ សុំគ្រប់គ្រងធ្វើជាកម្មសិទ្ធិស្របច្បាប់ពីពេលនេះតទៅ ។

បានស្តាប់ចំលើយរបស់ឈ្មោះ កង សុផល បន្ថែមថា : ខ្លួនតំណាងឱ្យខូវ សុខផាវ សូមបញ្ជាក់ថា ចុងចំលើយ ជុំ ហួង នៅវៀតណាមមិនពិតទេ ឯប័ណ្ណគ្រួសារ ទើបមានការតំរូវឱ្យធ្វើឆ្នាំ១៩៩៩នេះទេ បើខូវ សុខផាវ រៀបការជុំ ហួង តាំងពីឆ្នាំ១៩៨០ម្ល៉េះ ហេតុអ្វីទើបចូលនៅលើដី និងផ្ទះឆ្នាំ១៩៨៦ ? ឯកូនពីរនាក់ឈ្មោះជុំ វាសនា និង ជុំ សំណាង ពិតមែនតែមិនមែនកូន ជុំ ហួង មែន តែប័ណ្ណគ្រួសារដាក់ថា ជាកូនទៅហើយ តាមពិតកូនពីរនាក់នេះជាកូនចិញ្ចឹមកូនសុំមែន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ឈុន វីនីតា ជាមេធាវីការពារឱ្យដើមចោទឈ្មោះខូវ សុខផាវ បានលើកឡើងថា : ចំពោះអង្គហេតុ ក្រុមប្រឹក្សាបានជ្រាបច្បាស់ហើយ ខ្លួនលើកត្រួសៗទេ តាមគំនូសប្លង់ ខ្លួនមានឃើញថា ដីទំនាស់នៅខាងមុខ ឯដីនិងផ្ទះនៅពីក្រោយដីទំនាស់របស់ខូវ សុខផាវ មែន តែប្អូនតាន់ ហួង ឈ្មោះតាន់ យូរ ចូលទៅនៅហើយ ឯផ្ទះនិងដីទំនាស់សព្វថ្ងៃនេះ ខូវ សុខផាវ គាត់នៅ ចំណែកចុងចំលើយមានដីកន្លែងផ្សេង ហើយបែរលក់បាត់ ។ ដី និងផ្ទះទំនាស់ជាអចលនទ្រព្យរបស់យាយ ផៃ គឺ ពេលគាត់នៅរស់បានធ្វើប្រទានកម្មឱ្យកូនគាត់ឈ្មោះជុំ ហួង(ប្តីដើមចោទ)គឺមិនមែនមរតកទេ សូមតុលាការពិចារណាលើប្រទានកម្មចំពោះរឿង

នេះ ដើមចោទមានប័ណ្ណកម្មសិទ្ធិ និងភស្តុតាងត្រឹមត្រូវណាស់ ស្របតាមមាត្រា៨១ នៃច្បាប់ភូមិបាលផង មុនពេលចេញប័ណ្ណកម្មសិទ្ធិមានលិខិតអង្កេតដី ម្តេចមិនតវ៉ា គឺចុងចំលើយមិនតវ៉ាទេលើលិខិតអង្កេតដីដែលមានបញ្ជាក់ថា ដើមចោទមិនទាមទារដីទំនាស់ធ្វើកម្មសិទ្ធិនោះ ខ្លួនមិនដឹងទេ ខ្លួនមានតែប័ណ្ណកម្មសិទ្ធិប៉ុណ្ណោះ ។ សុំឱ្យដើមចោទមានសិទ្ធិគ្រប់គ្រងដី និងផ្ទះទំនាស់ធ្វើកម្មសិទ្ធិ និង សុំឱ្យចុងចំលើយរុះរើផ្ទះចេញពីដី ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ស៊ឹម ស៊ីថាន ជាមេធាវីការពារឱ្យឈ្មោះតាន់ ហួង បានលើកឡើងថា : រឿងនេះសាលាឧទ្ធរណ៍បានសំរេចយ៉ាងត្រឹមត្រូវទាំងពីរលើក ហើយពេលចុងក្រោយនេះតុលាការកំពូលអង្កេតខ្លួនឯងឃើញថា មានភស្តុតាងច្បាស់លាស់គួរទទួលស្គាល់តាន់ហួងជាម្ចាស់កម្មសិទ្ធិលើដី និងផ្ទះទំនាស់នេះហើយ ការពិតជុំ ហួង ក្តី ខូវ សុខផាវ ក្តី ពុំមានសិទ្ធិទាមទារយកដី និងផ្ទះទំនាស់ធ្វើកម្មសិទ្ធិបានទេ ព្រោះមិនមែនជាម្ចាស់កម្មសិទ្ធិ។មុនឆ្នាំ៧៩ ជុំ ហួង នៅវៀតណាមឯណោះ តាន់ ហួង និងយាយផៃ គី ព្រមទាំងចៅ២ទេ ចូលនៅលើដីទំនាស់នេះ ខ្លួនឯងមកនៅក្រោយគេ បែរជាដេញគេចេញ ។ការដែលតំណាងដើមចោទ និងមេធាវីដើមចោទថា មានភស្តុតាងត្រឹមត្រូវដើម្បីក្លាយជាកម្មសិទ្ធិនេះ ពុំត្រឹមត្រូវទេ តាមការពិត ដើមចោទមានឯកសារទាំងនេះមានលក្ខណៈបន្លំបោកប្រាស់ និងព្រលាំ ទាំងអស់ មិនមែនកាន់កាប់ដោយសន្តិភាពទេ ស្តែងចេញពីករណីនេះ អាជ្ញាធរភូមិ-ឃុំ ស៊ីយោដី មេភូមិជំទប់ទី១ ទី២ និងខាងស៊ីយោដី បញ្ជាក់ច្បាស់លាស់ហើយ ឯកសារជុំ ហួង ធ្វើបំណងចង់បានដីប៉ុណ្ណោះ តែត្រូវបានអាជ្ញាធរទប់ស្កាត់ ហេតុនេះហើយបានជាមុនធ្វើប័ណ្ណលើលិខិតអង្កេតដីខាងជំនាញឱ្យខូវ សុខផាវ បញ្ជាក់ថាខ្លួននឹងមិនទាមទារដីទំនាស់ធ្វើកម្មសិទ្ធិទេ ចុះបើដីខ្លួនឯងចាំបាច់បញ្ជាក់ធ្វើអ្វី ? លិខិតផ្ទេរសិទ្ធិពីយាយផៃ គី ទៅជុំ ហួង ពេលនេះគឺវង្វេងទៅហើយ អាយុ៩៥ឆ្នាំថ្លោយទៅហើយ ដូចនេះច្បាប់មិនទទួលស្គាល់ដាច់ខាត ។

យោងតាមការចូលកាន់កាប់រស់នៅពិត សាក្សី ឯកសារភស្តុតាងរបស់អាជ្ញាធរមូលដ្ឋាន ស្របតាមមាត្រា១២៣,៦២,៦៣ និង ៧៤ នៃច្បាប់ភូមិបាល ចុងចំលើយមានសិទ្ធិជាម្ចាស់លើដីទំនាស់ និងផ្ទះទំនាស់ហើយ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីនៃគូភាគី .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៦៨ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ របស់អ្នកស្រីខូវ សុខផារ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២២៦ នៃនីតិវិធីព្រហ្មទណ្ឌដែលអាចយកមកអនុវត្តក្នុងរឿងរដ្ឋប្បវេណីបានផងដែរ ។

- យល់ឃើញថា ឈ្មោះជុំ ហួង ពិតជាកូនបង្កើតរបស់យាយផៃ គី ប្រាកដមែន តែមិនបានរស់នៅជាមួយម្តាយជាប្រចាំទេ ដោយពីដំបូងរស់នៅឯប្រទេសវៀតណាម ហើយពេលត្រឡប់មកវិញបានរស់នៅឯឃុំអណ្តូងខ្មែរត្រើយខាងលិច និងក្រោយមកក៏បានមករស់នៅជាមួយម្តាយឯខេត្តកំពតវិញ ។ ក្រោយពីរៀបការជាមួយអ្នកស្រី ខូវ សុខផារ នៅឆ្នាំ១៩៩០មក រដ្ឋអំណាចបានចែកដីមួយកន្លែងផ្សេងទៀតឱ្យលោកជុំ ហួង គ្រប់គ្រងជាកម្មសិទ្ធិដែលមានប័ណ្ណសំគាល់កម្មសិទ្ធិលេខ $A_3$ ០១៦៧ ហើយមានទីតាំងនៅក្បែរដីទំនាស់ដែរ ។

- យល់ឃើញថា តាមចំលើយបំភ្លឺរបស់លោកភូ ស៊ីន ជាអតីតមេភូមិ និងលោកនុង នឹម ជាមេឃុំកំពង់បាយតាមកំណត់ហេតុចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ នៅតុលាការកំពូល ក៏ដូចជាតាមការបញ្ជាក់របស់លោកស៊ិន ហាក់ ជំទប់លេខ ៣ ឃុំកំពង់បាយ តាមលិខិតចុះថ្ងៃទី១៤ ខែមិនា ឆ្នាំ១៩៩៨ លោកអ៊ីវ ម៉ារ៉េត មេភូមិកំពង់បាយខាងជើង តាមលិខិតចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៨ និងលិខិតបញ្ជាក់បំភ្លឺរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្តកំពតលេខ ០១ ដនកស ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០២ មានន័យប្រហាក់ប្រហែលគ្នាថា ដី និងផ្ទះទំនាស់ត្រូវបានលោកស្រីផៃ គី និងឈ្មោះតាន់ ហុង រួមជាមួយប្អូនៗ បានចូលកាន់កាប់ និងរស់នៅតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ដែលការបំភ្លឺនេះ មានភាពស៊ីសង្វាក់គ្នាទៅនឹងពាក្យស្នើសុំកាន់កាប់ដីរបស់អ្នកស្រីផៃ គី ដែលបានធ្វើនៅឆ្នាំ១៩៨៩ និងលិខិតប្រគល់អចលនទ្រព្យចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩២ និងលិខិតអនុញ្ញាតឱ្យឈ្មោះតាន់ ហុង ធ្វើអាជីវកម្មនៅផ្ទះទំនាស់តាំងតែពីឆ្នាំ១៩៨៦ ដូចនេះឃើញថាថ្វីត្បិតតែនៅក្នុងប័ណ្ណសំគាល់កម្មសិទ្ធិមានឈ្មោះជុំហួង ជាម្ចាស់មែន តែកម្មសិទ្ធិករស្របច្បាប់ គឺមានតែអ្នកស្រីផៃ គី ប៉ុណ្ណោះ ។

- យល់ឃើញថា អ្នកស្រី ផៃ គី ដែលជាកម្មសិទ្ធិករស្របច្បាប់ ក៏ដូចជាលោកជុំ ហួង ដែរ បានទទួលមរណភាពហើយ ដូចនេះទ្រព្យរបស់មរតកជននេះ នឹងធ្លាក់ទៅសន្តតិជន ដែលក្នុងនោះមានឈ្មោះតាន់ ហុង,តាន់ ស៊ីម,តាន់ ហ្គេច,តាន់ ឆាយ,តាន់ មួយ,និងតាន់ យូ, ជុំ ឆាយ ,ជុំ ឡេង ,ជំ ជី និង ជុំ ហ៊ាង ហើយការដែលអ្នកស្រីខូវ សុខផារ ប្តឹងទាមទារដោយសំអាងលើលិខិតបណ្តាំមរតករបស់ឈ្មោះជុំ ហួង នោះជាការពុំត្រឹមត្រូវទេ ដោយហេតុថា លោកជុំ ហួង

ពុំមែនជាកម្មសិទ្ធិករស្របច្បាប់ ហើយអ្នកស្រីផ្ទាល់ពុំមែនជាសហសន្តតិជននៃអ្នកស្រី ផៃ គី និង ម៉្យាងទៀត កាលពីធ្វើកំណត់ហេតុអង្កេតដី អ្នកស្រីបានសន្យាថា មិនទាមទារទ្រព្យនេះទេ ។

- យល់ឃើញថា ការដែលតំណាងអ្នកស្រីខូវ សុខផាវ ក៏ដូចមេធាវីរបស់អ្នកស្រីដែរ ដែលលើកឡើងអំពីប្រទានកម្មចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩២ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះ តាមការបំភ្លឺរបស់លោកនុង នឹម ជាមេឃុំ ក៏ដូចជាលោក ភូ ស៊ីន ជាមេភូមិ តាមកំណត់ហេតុចុះ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ដែលជាអ្នកចុះហត្ថលេខា បានឃើញលើលិខិតប្រទានកម្មដោយផ្ទាល់ បញ្ជាក់ថា លោកជុំ ហួង បានបង្ខំឱ្យខ្លួនចុះហត្ថលេខានិងបានសន្យាថា គ្រាន់តែឈរឈ្មោះជាជំហរ សំរាប់បែងចែកឱ្យក្មួយៗតែប៉ុណ្ណោះ ដូចនេះឃើញថា ប្រទានកម្មចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩២ ពិតជាមានវិការៈ ហើយលោកជុំ ហួង មិនអាចក្លាយជាកម្មសិទ្ធិករស្របច្បាប់ ដែលអាចធ្វើមរតក សាសន៍នូវទ្រព្យអ្នកដទៃបានឡើយ ។

- យល់ឃើញថា ឈ្មោះតាន ឆាយ ក៏ជាសហសន្តតិជនម្នាក់ដែរ ហើយសាលាឧទ្ធរណ៍ មិនទាន់បានទទួលស្គាល់ និងសំរេចប្រគល់ចំណែកដែលត្រូវទទួលបាននៅឡើយ តែភាគីអ្នកស្រី តាន់ ហុង មិនបានប្តឹងសាទុក្ខឡើយ ដូចនេះតុលាការកំពូលមិនអាចពិចារណាបានឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១១២"ឈ"ចុះថ្ងៃទី០៩ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

**ហេតុដូចនេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី**

១-ទទួលបណ្តឹងសាទុក្ខលេខ២៦៨ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ របស់អ្នកស្រីខូវ សុខផាវ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ១១២"ឈ" ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០២ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រី ខូវ សុខផាវ បានបង់នៅតុលាការកំពូលចំនួន ១៩០០០៛ គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០៛ សំរាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

បង្គាប់ឱ្យអ្នកស្រីខូវ សុខផាវ បង់ពន្ធសមាមាត្រចំនួន ១% តាមការកំណត់របស់សាលា ឧទ្ធរណ៍ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៥ ។

*សាលដីការដ្ឋប្បវេណីលេខ ៣២៦ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ របស់តុលាការកំពូល ។*